**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**លេខ**.........................

# សេចក្តីប្រកាសព័ត៌មាន

## អ្នកនាំពាក្យ ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា

អ្នកនាំពាក្យក្រសួងការពារជាតិ សូមប្រកាសបដិសេធនិងច្រានចោលទាំងស្រុងនូវព័ត៌មានផ្សាយតាមវិទ្យុអាស៊ីសេរីកាលពីព្រឹកថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១៧ ដែលថាយោធាឡាវបានបន្ថែមកម្លាំង និងជីកលេណដ្ឋានថ្មីៗតាមខ្សែបន្ទាត់ព្រំដែន ត្រង់ចំណុចតំបន់អូរតាង៉ាវ និងអូរអាឡៃ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ។

អ្នកនាំពាក្យក្រសួងការពារជាតិ ចាត់ទុកព័ត៌មានផ្សាយតាមវិទ្យុអាស៊ីសេរីកាលពីព្រឹកនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ នោះថាជាដំណឹងគ្មានមូលដ្ឋានបំផ្លើសការពិត មានចេតនាញុះញង់ ដែលធ្វើឲ្យមានការភាន់ច្រឡំដល់សាធារណជន មុនពេលការបោះឆ្នោតឃុំ-សង្កាត់ ព្រមទាំងធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងល្អរវាងប្រទេសជិតខាងទាំងពីរ ។

អ្នកនាំពាក្យក្រសួងការពារជាតិ សូមជម្រាបសាធារណជនជ្រាបថាបច្ចុប្បន្ននេះកងយោធពលខេមរភូមិន្ទ កំពុងតាំងមូលដ្ឋានឈរជើងយ៉ាងរឹងមាំតាមបណ្តោយព្រំដែនកម្ពុជា-ឡាវ ក៏ដូចជាព្រំដែនជាប់ជាមួយប្រទេសជិតខាងដ៏ទៃទៀត ដោយប្រកាន់ខ្ជាប់នូវភារកិច្ចការពារជាតិមាតុភូមិយ៉ាងមឹងម៉ាត់ មិនបណ្តោយឲ្យទាហានឡាវ ឬកងទ័ពបរទេសណាមួយមកតាំងមូលដ្ឋានក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដូចការផ្សព្វផ្សាយព័ត៌មានគ្មានមូលដ្ឋានរបស់វិទ្យុអាស៊ីសេរីកាលពីព្រឹកថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៧នោះបានឡើយ ។

*ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៧*

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤ អ៊ីម៉ែល៖ generalsec@mod.gov.kh